**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោត ទន្លេមេគង្គ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣៩អនក្រ.បក ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម ឌុច ស៊ីសុខានា | សមាជិក កសសស (OBSES) | ជាប្រធាន |
| ២- ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- ឯកឧត្តម ឈើ ឬទ្ធី | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- ឯកឧត្តម ខាំ ឃឿន | អភិបាលខេត្តក្រចេះ | អនុប្រធាន |

| | | |
|---|---|---|
| ៥-ឯកឧត្តម **ឡុង ផល** | អភិបាលរងទី ១ ខេត្តស្ទឹងត្រែង | អនុប្រធាន |
| ៦-ឯកឧត្តម **ដួង លឿង** | មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ៧-ឯកឧត្តម **ណៅ ធូក** | សមាជិក កសសស និងជាប្រធាននាយកដ្ឋានជលផល | សមាជិក |
| ៨-ឯកឧត្តម **ចាន់ រ៉ាស៊ី** | អគ្គលេខាធិការរង កសសស | សមាជិកអចិន្ត្រៃយ៍ |
| ៩-លោក **ស្វ នាក់** | ស្នងការនគរបាលខេត្តក្រចេះ | សមាជិក |
| ១០-លោក **ឆា គៀត** | មេបញ្ជាការកងរាជអាវុធហត្ថខេតខេត្តក្រចេះ | សមាជិក |
| ១១-លោក **មុត ម៉ៅ** | ស្នងការនគរបាលខេត្តស្ទឹងត្រែង | សមាជិក |
| ១២-លោក **សៀន ម៉ុនរិទ្ធ** | មេបញ្ជាការកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង | សមាជិក |
| ១៣-លោក **កែវ រតនៈ** | នាយកខុទ្ទកាល័យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |

**មាត្រា ២.-**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

- ធ្វើការអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីតម្លៃនៃសត្វផ្សោត ដែលជិតផុតពូជ និងតម្លៃបេតិកភ័ណ្ឌធម្មជាតិរបស់សត្វផ្សោតនៅតំបន់ទេសចរណ៍សត្វផ្សោត ឱ្យមានការអភិរក្ស និងអភិវឌ្ឍ ប្រកបដោយនិរន្តរភាព
- ចាត់តាំងមន្ត្រីភ្នាក់ងារប្រចាំការនៅតំបន់មានសត្វផ្សោត ទាំងលើគោក និងក្នុងទន្លេ ដោយសហការជាមួយសហគមន៍ និងអាជ្ញាធរដែនដីមូលដ្ឋាន
- ស្វែងរកជំនួយ សម្ភារៈ និងថវិកា ក្នុងនិងក្រៅប្រទេស ដើម្បីបំរើការងារអភិរក្ស និងជួយបង្កលក្ខណៈឱ្យប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានមានមុខរបរផ្សេងជំនួសការនេសាទត្រី ក្នុងតំបន់មានសត្វផ្សោត
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការកំណត់ទំហំនៃតំបន់អភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោត
- រៀបចំសេចក្តីព្រាងផែនការមេ និងផែនការសកម្មភាព ក្នុងការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ
- សហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីបំរើគោលដៅអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតប្រកបដោយនិរន្តរភាព
- ធ្វើរបាយការណ៍ជាប្រចាំតាមកាលកំណត់អំពីលទ្ធផលការងារ ជូនអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៣.-**

- គណៈកម្មការនេះមានទីតាំងទីស្នាក់ការកណ្តាលនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានទីស្នាក់ការជាសាខានៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ព្រមទាំងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការ-គណៈរដ្ឋមន្ត្រី
- សមាជិកនៃគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

- ប្រធានគណៈកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា ៤.-**

គណៈកម្មការនេះមានថវិកាសម្រាប់ចំណាយក្នុងសកម្មភាពការងាររបស់ខ្លួន នៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងមានប្រភពចំណូលមកពីជំនួយអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងចំណូលផ្សេងៗទៀត។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ